**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៤ សរ

# សារាចរ

# ស្តីពី

# ការពង្រឹងបន្ថែមលើការងារគ្រប់គ្រងវិស័យសកម្មភាពមីន

សកម្មភាពបោសសម្អាតមីនត្រូវបានរាជរដ្ឋាភិបាលកម្ពុជាកំណត់យកធ្វើជាអាទិភាពចម្បង សំដៅរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងជំរុញការអភិវឌ្ឍ។ រាជរដ្ឋាភិបាលបានកំណត់នូវចក្ខុវិស័យយ៉ាងច្បាស់លាស់ គឺ **«ប្រទេសកម្ពុជាគឺជាប្រទេសដែលគ្មានមីន ការគំរាមកំហែងដោយសំណល់ជាតិផ្ទុះពីសង្គ្រាម ត្រូវបានកាត់បន្ថយឱ្យនៅកម្រិតអប្បបរមា ហើយការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងការអភិវឌ្ឍមនុស្សអាចប្រព្រឹត្តទៅដោយសុវត្ថិភាព»**។ តាមរយៈចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាក់លាក់ ដោយកំណត់យកឆ្នាំ២០២៥ ជាឆ្នាំដែលកម្ពុជាគ្មានគ្រាប់មីន។ ដើម្បីឈានទៅសម្រេចបានជោគជ័យតាមយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលធ្វើការណែនាំ ដូចខាងក្រោម៖

១. ប្រតិបត្តិករបោសសម្អាតមីនជាតិ អន្តរជាតិទាំងអស់ ត្រូវបន្តពង្រឹងគុណភាព សុវត្ថិភាព គណនេយ្យភាព និងប្រសិទ្ធភាពចំពោះការងាររបស់ខ្លួន ដើម្បីទទួលបាននូវការគាំទ្រ និងការជឿទុកចិត្តពីដៃគូពាក់ព័ន្ធ។

២. ប្រតិបត្តិករជាតិ អន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ ស្តង់ដាជាតិសកម្មភាពមីន ផែនការ គោលការណ៍ណែនាំ និងសេចក្តីណែនាំនានា ដែលចេញដោយអាជ្ញាធរមីន។

៣. ប្រតិបត្តិករជាតិ អន្តរជាតិទាំងអស់ ត្រូវបន្តពង្រឹង លើកកម្ពស់កិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាមួយអាជ្ញាធរមីន ជាពិសេសការផ្តល់ទិន្នន័យ និងព័ត៌មាន រួមមាន ព័ត៌មានស្តីពីហិរញ្ញវត្ថុ សម្ភារៈ កម្លាំងប្រតិបត្តិការ និងជំនួយបច្ចេកទេស ដើម្បីឱ្យអាជ្ញាធរមីនមានលទ្ធភាពបូកសរុប និងរាយការណ៍ជូនរាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ។

៤. ប្រតិបត្តិករជាតិ អន្តរជាតិទាំងអស់ ត្រូវលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមីន និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីធានានូវការរៀបចំនិងការអនុវត្តផែនការបោសសម្អាតមីនប្រចាំឆ្នាំប្រកបដោយប្រសិទ្ធភាពខ្ពស់។

៥. អាជ្ញាធរមីនត្រូវផ្តល់ជាត្រីវិស័យដល់ប្រតិបត្តិករទាំងអស់ ដើម្បីគោរពឱ្យបាននូវគោលការណ៍ណែនាំសម្រាប់ការធ្វើផែនការបោសសម្អាត និងបន្តដឹកនាំតាមការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ ឱ្យមានប្រសិទ្ធភាពខ្ពស់។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរមីន ប្រតិបត្តិករបោសសម្អាតមីន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃពុធ ៧ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ